# មណ្ឌលវប្បធម៌ខ្មែរប្រចាំប្រទេសស្វីស

**Khmer Kulturzentrum in der Schweiz**
**Centre Culturel Khmer en Suisse**

Kirchgasse 12, 5746 Walterswil SO / Tel. 044 636 59 00 / www.khmer-kulturzentrum.ch


## បុណ្យផ្កាប្រាក់ស្វីសាមគ្គី ស្ពានអាងទឹក ជួយកសិករ

ខ្ញុំព្រះករុណាអាត្មាភាព យើងខ្ញុំទាំងអស់គ្នា ជាព្រះសង្ឃ លោកអាចារ្យ និងគណៈកម្មការ **មណ្ឌលវប្បធម៌ខ្មែរ** វត្ត **សង្ឃារាម** បានមូលមតិគ្នាជាឯកច្ឆ័ន្ទ ប្រារព្ធធ្វើ **បុណ្យផ្កាប្រាក់ស្វីសាមគ្គី** ដើម្បីជួយស្ថាបនាអាងទឹកធំមួយ ជាប្រយោជន៍ ស្រោចស្រពដំណាំ និងការប្រើប្រាស់ទឹក ដែលប្រជាជនចំនួន ៨៣៦ គ្រួសារ នៅភូមិស្លែង ភូមិគោកព្រេច និងភូមិត្រពាំងព្រីង ស្រុកគីរីវង់ ខេត្តតាកែវ ត្រូវការ។

អាស្រ័យហេតុ ដូចបានប្រគេន និងជំរាបជូនខាងលើ ខ្ញុំព្រះករុណាអាត្មាភាព យើងខ្ញុំ ទាំងអស់គ្នា មានកិត្តិយស សូមគោរពនិមន្ត និងអញ្ជើញ ព្រះតេជគុណ លោក លោកស្រី អ្នកនាងកញ្ញា ចូលរួមចាប់មគ្គផលក្នុងកម្មវិធីបុណ្យ តាមកម្លាំងសទ្ធាជ្រះថ្លារៀងៗខ្លួន កុំបី អាក់ខានឡើយ ។

**ទីកន្លែង:** **មណ្ឌលវប្បធម៌ខ្មែរ** វត្ត **សង្ឃារាម**, Kirchgasse 12, 5746 Walterswil SO

**ពេលវេលា:** **ថ្ងៃសៅរ៍ ទី ០៩ ខែ ឧសភា ឆ្នាំ ២០១៥** / Samstag, 09.05.2015

### កម្មវិធីបុណ្យ

ម៉ោង ១០.00 ជួមជុំពុទ្ធបរិស័ទជិតឆ្ងាយ ធ្វើបទនមស្សការ សមាទានសីល

ម៉ោង១១00. វេរភត្តាហារប្រគេនដល់ព្រះសង្ឃ

ម៉ោង១២.00 ទទួលទានបាយ ថ្ងៃត្រង់

ម៉ោង១៣.៣០ សម្តែងធម្មទេសនា និងសរុបបច្ច័យផ្កាប្រាក់